# ព្រះរាជក្រឹត្យ

នស/រកត/០៧២០/ ៧៦៦

## ស្ដីពី
## ការកំណត់ងារសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាតាមមុខតំណែង

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានការសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២០

## ត្រាស់បង្គាប់

**មាត្រា១ :** ព្រះរាជក្រឹត្យនេះមានគោលបំណងកំណត់នូវងារ សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ទៅតាមមុខតំណែងដែលកំពុងបំពេញមុខងារនៅតាមសាលាជម្រះក្ដី និងអយ្យការអមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២:** កំណត់ឱ្យមានងារជា ឯកឧត្តម ឬលោកជំទាវ សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា ដែលមានមុខតំណែងនៅតាមសាលាជម្រះក្ដី និងអយ្យការអមសាលាជម្រះក្ដី ដូចខាងក្រោម:

ក- ប្រធាន អនុប្រធាន និងចៅក្រមទាំងអស់នៃតុលាការកំពូល
ខ- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាទាំងអស់នៃមហាអយ្យការអមតុលាការកំពូល
គ- ប្រធាន និងអនុប្រធាននៃសាលាឧទ្ធរណ៍

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឃ- អគ្គព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍

ង- ប្រធានសាលាដំបូងរាជធានី-ខេត្ត

ច- ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។

**មាត្រា៣ :** ចៅក្រម និងព្រះរាជអាជ្ញា ដែលទទួលបានការតែងតាំងមុខតំណែងមុនព្រះរាជក្រឹត្យនេះចូលជាធរមាន និងមានមុខតំណែងដូចដែលបានកំណត់ក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ត្រូវទទួលបាននូវងារជាឯកឧត្តម ឬលោកជំទាវ ដោយស្វ័យប្រវត្តិ។

**មាត្រា៤ :** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស/រកត.០៧២០/៧៥៥

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**